ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អ អ ក

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ✓ អអក

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធី EAC App ពេញលេញសម្រាប់អ្នកប្រើប្រាស់អគ្គិសនី នៅតំបន់ផ្គត់ផ្គង់របស់អ្នកកាន់អាជ្ញាបណ្ណអគ្គិសនីឯកជន

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នក-ឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅតំបន់ផ្គត់ផ្គង់របស់អ្នកកាន់អាជ្ញាបណ្ណអគ្គិសនីឯកជនទាំងអស់មេត្តាជ្រាបថា ពេលនេះអាជ្ញាធរអគ្គិសនីកម្ពុជាបានដាក់ឱ្យប្រើប្រាស់កម្មវិធី EAC App ពេញលេញដើម្បីឆ្លើយតបនឹងតម្រូវការប្រើប្រាស់របស់អ្នកប្រើប្រាស់អគ្គិសនីឋិតក្នុងតំបន់ផ្គត់ផ្គង់របស់អ្នកកាន់អាជ្ញាបណ្ណអគ្គិសនីឯកជន ។

តាមរយៈកម្មវិធី EAC App នេះ អ្នកប្រើប្រាស់អាចពិនិត្យតាមដានការប្រើប្រាស់អគ្គិសនីរបស់ខ្លួន, ទូទាត់ថ្លៃប្រើប្រាស់អគ្គិសនីប្រចាំខែ, ស្នើសុំភ្ជាប់ចរន្តថ្មី, ស្នើសុំដំឡើងកម្លាំងប្រើប្រាស់, ស្នើសុំផ្លាស់ប្តូរព័ត៌មានទូទៅ, ស្នើសុំភ្ជាប់ចរន្តឡើងវិញ, រាយការណ៍បញ្ហាទៅអ្នកផ្គត់ផ្គង់អគ្គិសនី, ទទួលបានព័ត៌មានអំពីការផ្គត់ផ្គង់អគ្គិសនី និងព័ត៌មានផ្សេងៗទៀតអំពីវិស័យអគ្គិសនី ។

អាស្រ័យហេតុនេះ សូមសម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ដែលជាអ្នកប្រើប្រាស់អគ្គិសនីនៅតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់អ្នកកាន់អាជ្ញាបណ្ណអគ្គិសនីឯកជនទាំងអស់មេត្តាជ្រាប និងទាញយកកម្មវិធី EAC App សម្រាប់ប្រើប្រាស់ ទាំងតាមប្រព័ន្ធប្រតិបត្តិការ Android និង IOS ។

ថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥

សូមស្កែនដើម្បី
ទាញយកកម្មវិធី EAC App

# EAC App

## សម្រាប់អ្នកប្រើប្រាស់ក្នុងតំបន់របស់អ្នកផ្គត់ផ្គង់អគ្គិសនីឯកជន

## របៀបដំឡើង EAC App

ដំបូងសូមចូលទៅ Play Store ឬ App Store រួច វាយពាក្យ **EAC App** ក្នុងប្រអប់ Search បន្ទាប់មក ចុចលើ EAC App រួចចុច Install ។

Download on the App Store

ANDROID APP ON Google play

សូមស្កេននៅទីនេះដើម្បីទទួលបានកម្មវិធី **EAC App**

## របៀបបង្កើតគណនីថ្មី

សូមចុច **បង្កើតគណនីថ្មី** បន្ទាប់មកសូមបំពេញព័ត៌មានផ្ទាល់ខ្លួន និងចុច ✓ ខ្ញុំយល់ព្រម... រួចចុច **បង្កើត** ប្រព័ន្ធនឹងផ្ញើសារ OTP ទៅលេខទូរស័ព្ទដៃលោកអ្នក រួចសូម **បញ្ចូលលេខកូដ OTP** បួនខ្ទង់ បន្ទាប់មកចុច **ផ្ទៀងផ្ទាត់** បន្ទាប់មកសូម **កំណត់លេខកូដ PIN** បួនខ្ទង់ដើម្បីធ្វើប្រតិបត្តិការមុខងារសំខាន់ៗក្នុងកម្មវិធី រួចចុច **យល់ព្រម** ដូចរូបខាងក្រោម៖



## របៀបភ្ជាប់គណនី ដើម្បីពិនិត្យ និងតាមដានការប្រើប្រាស់ថាមពលអគ្គិសនី

សូមចុច **ភ្ជាប់គណនីថ្មី** រួចសូម **បំពេញលេខកូដ PIN** បួនខ្ទង់របស់លោកអ្នក រួចសូម **បំពេញលេខកូដអតិថិជន** ដែលមាននៅលើវិក្កយបត្រ( ឧ. 123-456789) រួចចុច **បន្ទាប់** សូម **បំពេញលេខវិក្កយបត្រ** ( ឧ. CINV25-345678) ចំនួនពីរខែផ្សេងគ្នា រួចចុច **ភ្ជាប់** ដូចរូបខាងក្រោម៖



សូមចុចភ្ជាប់គណនី › សូមបញ្ចូល PIN 4 › បញ្ចូលលេខអតិថិជន › បញ្ចូលលេខវិក្កយបត្រ២ខែ